សហគ្រិនខ្មែរ KHMER ENTERPRISE

(Energy)Lab

សេចក្តីប្រកាសព័ត៌មាន

# សហភាពអឺរ៉ុប និងសហគ្រិនខ្មែរគាំទ្រភាពជាដៃគូសម្រាប់នវានុវត្តន៍ក្នុងវិស័យថាមពលស្អាត ក្នុងវិស័យកសិជលផល

សហគ្រិនខ្មែរគឺជាស្ថាប័នក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) និង EnergyLab ដែលជាអ្នកបណ្តុះបណ្តាលធុរកិច្ចបង្កើតថ្មីផ្នែកថាមពលស្អាតតែមួយគត់នៅប្រទេសកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូដើម្បីគាំទ្រដល់ធុរកិច្ចបង្កើតថ្មីផ្នែកថាមពលស្អាតក្នុងវិស័យកសិកម្ម នេសាទ និងវារីវប្បកម្មនៅក្នុងប្រទេសកម្ពុជា ដោយទទួលបានកញ្ចប់ថវិការជំនួយពីសហភាពអឺរ៉ុប។

ភាពជាដៃគូនេះមានគោលបំណងលើកកម្ពស់គំនិតអាជីវកម្មរបស់សហគ្រិនផ្នែកថាមពលស្អាតក្នុងការអភិវឌ្ឍផលិតផលប្រកួតប្រជែង ដែលឆ្លើយតបទៅនឹងតម្រូវការថាមពលរបស់សហគ្រាសកសិជលផលនៅតំបន់បឹងទន្លេសាប។ EnergyLab នឹងជ្រើសរើសធុរកិច្ចបង្កើតថ្មីផ្នែកថាមពលស្អាត ចំនួន ៥ - ១០ ដើម្បីចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលធុរកិច្ចបង្កើតថ្មី រយៈពេល ១ ឆ្នាំ ដើម្បីណែនាំអាជីវកម្មទាំងនោះ ជាមួយនឹងការបណ្តុះបណ្តាលយ៉ាងជិតដល់ ការណែនាំ និងការប្រឹក្សាយោបល់មួយទល់នឹងមួយ ។ សហគ្រិនខ្មែរនឹងផ្តល់ថវិកា "ជំនួយវិនិយោគដំបូង" ទៅដល់ធុរកិច្ចបង្កើតថ្មីដែលត្រូវបានជ្រើសរើស សម្រាប់ការបង្កើតគំរូផលិតផលសាកល្បង ផ្នែកលក់ ផ្នែកទីផ្សារ និងយុទ្ធសាស្រ្តអភិវឌ្ឍអាជីវកម្ម។

លោកបណ្ឌិត ឈៀង វណ្ណមុនិណ្ណ នាយកប្រតិបត្តិសហគ្រិនខ្មែរ បានមានប្រសាសន៍ថា ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហគ្រិនខ្មែរមានចក្ខុវិស័យដើម្បីក្លាយជាវេទិកាជាតិសម្រាប់លើកកម្ពស់សហគ្រិនភាព។ លោកបានបន្តថា ភាពជាដៃគូនេះមានភាពសមស្របទៅនឹងការគាំទ្រដល់ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងជាវិស័យអាទិភាពមួយរបស់សហគ្រិនខ្មែរ ដែលមានវិស័យកសិ-ឧស្សាហកម្ម "សហគ្រិនខ្មែរចង់បង្កើន វិនិយោគ និងគាំទ្រអាជីវកម្មដែលទទួលបានជោគជ័យនៅក្នុងវិស័យនេះ"។ តាមរយៈកម្មវិធីនេះ ធុរកិច្ចបង្កើតថ្មីអាចទទួលបានការគាំទ្រដែលពួកគេត្រូវការដើម្បីកែប្រែគំនិតអាជីវកម្មទៅជាអាជីវកម្មជាក់ស្តែង និងភាពរីកចម្រើន ក៏ដូចជាទាក់ទាញការវិនិ យោគទុនផងដែរ។ "សហគ្រិនខ្មែរមានបំណងជួយទាក់ទាញអ្នកវិនិយោគផ្សេងៗដើម្បីទទួលបានជោគជ័យក្នុងរយៈពេលវែង"ប្រសាសន៍របស់លោកបណ្ឌិត វណ្ណមុនិណ្ណ។

កម្មវិធីបណ្តុះបណ្តាលធុរកិច្ចបង្កើតថ្មីរបស់ EnergyLabគឺជាផ្នែកមួយនៃកម្មវិធី "SWITCH to Solar" ដែលទទួលបានថវិកាតាមរយៈកម្មវិធីជំនួយ SWITCH-Asia របស់សហភាពអឺរ៉ុប ដឹកនាំដោយ People in Need និងរួមសហការជាមួយក្រុមហ៊ុន Sevea។

លោកស្រី Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា "ការគាំទ្ររបស់យើងនឹងជួយជម្រុញឱ្យសហគ្រិនកម្ពុជាអភិវឌ្ឍបច្ចេកវិទ្យាបៃតងថ្មី និងបង្កើតដំណោះស្រាយជំនួញ សម្រាប់វិស័យកសិកម្មវារីវប្បកម្ម និងនេសាទ។ នវានុវត្តន៍ដោយប្រើថាមពលស្អាតនៅក្នុងខ្សែចង្វាក់គុណតម្លៃអាចជួយអាជីវកម្មនៅតំបន់ជនបទពង្រីកអាជីវកម្មរបស់ខ្លួន ពង្រឹងភាពប្រកួតប្រជែង និងក្រាលថ្នាលសម្រាប់ការរើបឡើងនៃសេដ្ឋកិច្ចដោយផ្អែកលើបច្ចេកវិទ្យាបៃតង។"

កម្មវិធីបណ្តុះបណ្តាលធុរកិច្ចបង្កើតថ្មីផ្អែកថាមពលស្អាតក្នុងវិស័យកសិកម្ម និងវារីវប្បកម្មគាំទ្រសហគ្រិនចំនួន ៧ នាក់ដំបូងដែលកំពុងអភិវឌ្ឍន៍អាជីវកម្ម ដើម្បីបង្កើនផលិតកម្មវារីវប្បកម្ម និងកសិកម្ម និងបង្កើនប្រសិទ្ធភាពតម្លៃក្រោយប្រមូលផល ដូចជាការក្លាស្សេប្ញការសម្ងួតដោយពន្លឺព្រះអាទិត្យ។ ធុរកិច្ចបង្កើតថ្មីមួយដែលត្រូវបានជ្រើសរើសកំពុងធ្វើការលើឧបករណ៍ស្រូបពន្លឺព្រះអាទិត្យដើម្បីបង្កើនផលិតភាពនៃកសិដ្ឋានចិញ្ចឹមត្រី។ "ខ្ញុំជឿជាក់ថាបច្ចេកវិទ្យានេះអាចផ្លាស់ប្តូរការអនុវត្តនៅក្នុងវិស័យវារីវប្បកម្មបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា។ វានឹងជួយកសិករបង្កើនទិន្នផល និងបង្កើតប្រាក់ចំណូលបន្ថែមទៀត" ប្រសាសន៍របស់លោក ស៊ុម រី នៃក្រុមហ៊ុន Agricultural Technique។

លោក Antoine Denizart នាយកនៃគម្រោង SWITCH to Solar របស់ EnergyLab បានមានប្រសាសន៍ថា "ការសហការជាមួយសហគ្រិនខ្មែរ អនុញ្ញាតឱ្យយើងអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលរបស់យើង និងបង្កើនវឌ្ឍនភាពរបស់ធុរកិច្ចថ្មី ដើម្បីឆ្ពោះទៅរកភាពជោគជ័យ"។ លោក Antoine ក៏បានបន្តទៀតថា "ឱកាសក្នុងការបង្កើតតម្លៃជាមួយដំណោះស្រាយថាមពលស្អាតក្នុងវិស័យកសិកម្ម និងវារីវប្បកម្មមានច្រើនលើសលប់ ប៉ុន្តែគម្រោងទាំងនេះមានភាពស្មុគស្មាញ និងដំណោះស្រាយអាជីវកម្មល្អមានចំនួនតិចតួចក្នុងប្រទេសកម្ពុជា។ ពួកយើងមានសេចក្តីសោមនស្សរីករាយក្នុងការសហការជាមួយសហគ្រិនខ្មែរ ពីព្រោះតែការគាំទ្រពីសហគ្រិនខ្មែរនឹងជួយសហគ្រិនក្នុងការចាប់យកឱកាសទីផ្សារ ក្នុងខណៈបន្ធូរបន្ថយហានិភ័យក្នុងដំណើរការនវានុវត្តន៍របស់ពួកគេ"។

កម្មវិធីបណ្តុះបណ្តាលអាជីវកម្មថាមពលស្អាតក្នុងវិស័យកសិកម្ម និងវារីវប្បកម្មលើកទី ២ នឹងចាប់ផ្តើមទទួលយកពាក្យនៅខែសីហា ឆ្នាំ ២០២១ ។

**អំពីកម្មវិធី EU Switch to Solar**

កម្មវិធី EU Switch to Solar ត្រូវបានផ្តល់ថវិកាជំនួយដោយសហភាពអឺរ៉ុប ដើម្បីលើកស្ទួយកំណើនសេដ្ឋកិច្ចដោយប្រើបច្ចេកវិទ្យាបៃតង និងការបង្កើតការងារ ដោយជួយគាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យមក្នុងការអភិវឌ្ឍដំណោះស្រាយសូឡា និងថាមពលស្អាត ក្នុងខ្សែសង្វាក់កសិកម្ម និងនេសាទនៅតំបន់ទន្លេសាប។ កម្មវិធីនេះត្រូវបានអនុវត្តដោយអង្គការ People In Need, EnergyLab និង Sevea។ កម្មវិធីនេះទទួលបានថវិការដោយសហភាពអឺរ៉ុប និងភ្នាក់ងារអភិវឌ្ឍន៍សាធារណរដ្ឋឆែក និងដំណើរការដល់ឆ្នាំ២០២៤។
https://www.switch-asia.eu/project/switch-to-solar/

**អំពីសហគ្រិនខ្មែរ**

**សហគ្រិនខ្មែរ** គឺជាស្ថាប័នក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរំពឹងថានឹងក្លាយជាវេទិកាជាតិសម្រាប់លើកកម្ពស់សហគ្រិនភាពតាមរយៈការបង្កើតភាពជាដៃគូបែបសាធារណៈនិងឯកជន។ វិស័យដែលមានអាទិភាពរួមមាន កសិកម្ម ផលិតកម្ម សេវាកម្ម និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ត្រូវបានជួយជ្រោមជ្រែងដើម្បីគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច នវានុវត្តន៍ ការបង្កើនផលិតភាព និងការបង្កើតការងារ។

ដោយមានបេសកកម្មកសាងប្រព័ន្ធអេកូឡូស៊ីអោយមានភាពរស់រវើក **សហគ្រិនខ្មែរ**ផ្តោតលើកម្មវិធីធំៗ ចំនួន ៤ គឺ:

- ការលើកកំពស់សមត្ថភាពសម្រាប់ធុរកិច្ចបង្កើតថ្មី និងសហគ្រាសធុនតូចនិងមធ្យម តាមរយៈកម្មវិធីបណ្តុះបណ្តាលធុរកិច្ចបង្កើតថ្មីរួមបញ្ចូលគ្នា និងកម្មវិធីអភិវឌ្ឍជំនាញ ការណែនាំ ការអភិវឌ្ឍផលិតផល ដំណោះស្រាយឌីជីថល និងជំនួយផ្នែកច្បាប់
- ការលើកកម្ពស់វប្បធម៌សហគ្រិនភាព ដូចជាសកម្មភាពបង្កើតដោយសហគ្រិនខ្មែរ ព្រឹត្តិការណ៍សហគមន៍ ការធ្វើបទបង្ហាញ កម្មវិធីផ្សព្វផ្សាយ និងកន្លែងធ្វើការរួមគ្នា។
- ការផ្តល់មូលនិធិគ្រាប់ពូជ និងការវិនិយោគសម្រាប់ធុរកិច្ចបង្កើតថ្មីនៅដំណាក់កាលដំបូង និងសហគ្រាសធន់តូចនិងមធ្យម ដោយទទួលបានការគាំទ្រនូវយុទ្ធសាស្ត្រចាកចេញ
- បណ្តាញវេទិកាទំនាក់ទំនង រវាងអ្នកកសាងប្រព័ន្ធអេកូឡូស៊ី, VCs និងវិនិយោគិនក្នុងស្រុក និងអន្តរជាតិ ។

ព័ត៌មានលម្អិតមាននៅ https://khmerenterprise.info

**អំពី EnergyLab**

EnergyLab គឺជាអង្គការជួយគាំទ្រការពង្រីកទីផ្សារថាមពលស្អាតនៅក្នុងប្រទេសកម្ពុជា ដោយផ្តោតជាសំខាន់ឱ្យមានបរិស្ថានគាំទ្រ, នវានុវត្តន៍ និងសហគ្រិនភាពក្នុងវិស័យថាមពលស្អាត។ EnergyLab ដែលជាផ្នែកនៃគម្រោង EU Switch to Solar បានបង្កើតកម្មវិធីបណ្តុះបណ្តាលធុរកិច្ចបង្កើតថ្មីសម្រាប់ថាមពលស្អាតក្នុងវិស័យកសិជលផល ដើម្បីគាំទ្រការបង្កើតគំនិតថ្មី ការពិនិត្យឡើងវិញ និងការបង្កើតគំរូអាជីវកម្មថ្មីតាមរយៈ Hackathon, Pre-incubation និង Incubation programs។

ព័ត៌មានលម្អិតមាននៅ https://energylab.asia/ceagfishinc

**ព័ត៌មានទំនាក់ទំនង**

EnergyLab លោក Antoine Denizart ប្រធានគម្រោង Switch លេខទំនាក់ទំនង +៨៥៥ ៩៦ ៨០២ ៩៨១០ antoine@energylab.asia

**សហគ្រិនខ្មែរ** លោក Kong Somphyvatanak ប្រធានផ្នែកទីផ្សារនិងវិនិយោគ +៨៥៥ ៩៩ ៩១៦ ១៥១, somphyvatanak.kong@khmerenterprise.info

កម្មវិធី EU Switch to Solar លោក Laube Lukáš ប្រធានប្រចាំប្រទេសរបស់អង្គការ People In Need លេខទំនាក់ទំនង +៨៥៥ ៩៥ ៩៣១ ៦៧១, lukas.laube@peopleinneed.cz